SMALL BUSINESS MAJORITY

## គន្លឹះក្នុងការស្វែងរកប្រាក់កម្ចី និងចៀសវាងពីការកេងប្រវ័ញ្ចពីសំណាក់ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីកំឡុងពេលការរីករាលដាលមេរោគកូវីដ-១៩

នៅពេលលោកអ្នកកំពុងស្វែងរកប្រភពធនធានប្រាក់កម្ចី វាចាំបាច់ណាស់ក្នុងការស្វែងយល់អោយច្បាស់ពីក្រុមហ៊ុនផ្តល់ប្រាក់កម្ចីដែលលោកអ្នកចង់បានដើម្បីចៀសវាងពីការកេងប្រវ័ញ្ច និងលក្ខខ័ណ្ឌខ្ចីប្រាក់ដែលមិនត្រឹមត្រូវពីសំណាក់ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីខិលខូចមួយចំនួន។ បើទោះជាមានក្រុមហ៊ុនផ្តល់ប្រាក់កម្ចីជាច្រើនកំពុងព្យាយាមជួយដល់អាជីវកម្មខ្នាតតូចដែលកំពុងតែជួបការលំបាកក៏ដោយ មិនមែនគ្រប់ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីទាំងអស់សុទ្ធតែមានបទប្បញ្ញត្តិត្រឹមត្រូវចេញដោយរដ្ឋាភិបាលនោះទេ ដូច្នេះក្រុមហ៊ុនទុច្ចរិតមួយចំនួនអាចឆ្លៀតឱកាសកេងចំណេញលើអាជីវកម្មខ្នាតតូចរបស់លោកអ្នកដែលកំពុងតែអន្ទះសារក្នុងការស្វែងរកប្រាក់កម្ចីមកជួយស្រោចស្រង់មុខជំនួញ។ ក្រុមហ៊ុនទុច្ចរិតមួយចំនួនធ្វើការបោកបញ្ឆោតម្ចាស់អាជីវកម្មខ្នាតតូចដោយបន្លំជាក្រុមហ៊ុនផ្តល់ប្រាក់កម្ចីតាមរយៈកម្មវិធីជំនួយរបស់រដ្ឋាភិបាល។ លើសពីនេះទៅទៀត យើងសង្កេតឃើញថាមានប្រភេទនៃប្រាក់កម្ចីផ្សេងទៀតដែលមិនមានបទប្បញ្ញត្តិត្រឹមត្រូវ ដូចជា ប្រាក់កម្ចីបែបទូទៅធម្មតា ដែលមានដូចជា ប្រាក់កម្ចីតាមប្រព័ន្ធអ៊ិនធឺណិត ប្រាក់កម្ចីទូទាត់ជាមួយការលក់ផលិផល ប្រាក់កម្ចីដែលអាចបើកជាសាច់ប្រាក់សុទ្ធមុនសំរាប់អាជីវករយកទៅប្រើប្រាស់ (merchant cash advances) និងប្រាក់កម្ចីដែលមានរយៈពេលខ្លីផ្សេងៗទៀត។ វាក៏មានសារៈសំខាន់ផងដែរក្នុងការយល់ដឹងពីតួនាទីរបស់ឈ្មួញកណ្តាលក្នុងដំណើរការខ្ចីប្រាក់នេះ។ ឈ្មួញកណ្តាល មិនមែនជាអ្នកផ្តល់ប្រាក់កម្ចីដោយផ្ទាល់នោះទេ ប៉ុន្តែពួកគេមានតួនាទីជាជនទីបីឬជាអ្នកគួកជេរដើររកក្រុមហ៊ុនប្រាក់កម្ចី មកអោយលោកអ្នក ។

ប្រសិនបើអាជីវកម្មខ្នាតតូចរបស់លោកអ្នកត្រូវបានទទួលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩ ហើយលោកអ្នកកំពុងស្វែងរកថវិកាមកជួយទប់មុខជំនួញរបស់លោកអ្នកនោះ  ខាងក្រោមនេះគឺជាគន្លឹះ និងប្រភពព័ត៌មានសំខាន់ខ្លះៗដែលជួយនាំផ្លូវលោកអ្នកក្នុងដំណើរការខ្ចីលុយ និងបញ្ចៀសពីការកេងប្រវ័ញ្ចពីសំណាក់ក្រុមហ៊ុនប្រាក់កម្ចី។

### ប្រសិនបើលោកអ្នកកំពុងស្វែងរកប្រាក់កម្ចីតាមរយៈរដ្ឋបាលគ្រប់គ្រងនិងផ្តល់ជំនួយដល់អាជីវកម្មខ្នាតតូច (Small Business Administration)

- គ្រប់ ជំនួយប្រាក់កម្ចីសំរាប់ស្រោចស្រង់សេដ្ឋកិច្ចដែលរងផលប៉ះពាល់ពីគ្រោះទុរភិក្ស (Economic Injury Disaster Loans) ទាំងអស់សុទ្ធតែត្រូវបានចែកចាយតាមរយៈរដ្ឋបាលគ្រប់គ្រងនិងផ្តល់ជំនួយដល់អាជីវកម្មខ្នាតតូច ដែលហៅកាត់ថា អេស ប៊ី អេ (SBA)។ ដូច្នេះក្រៅពី រដ្ឋបាលអេស ប៊ី អេ គ្មានក្រុមហ៊ុនផ្តល់ប្រាក់កម្ចីណាត្រូវបានអនុញ្ញាត្តិអោយផ្តល់ប្រាក់កម្ចីទាំងនេះទេ។ សូមលោកអ្នកចៀសវាងការចាញ់បោក ពីសំណាក់ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីដែលបន្លំអះអាងថាពួកគេនឹងអាចជួយផ្តល់នូវជំនួយប្រាក់កម្ចីសំរាប់ស្រោចស្រង់សេដ្ឋកិច្ចដែលរងផលប៉ះពាល់ពីគ្រោះទុរភិក្ស របស់ រដ្ឋបាល អេស ប៊ី អេ បានអោយសោះ។

- រដ្ឋបាល អេស ប៊ី អេ នឹងមិនទំនាក់ទំនងមកលោកអ្នកទាក់ទងកម្មវិធីប្រាក់កម្ចី៧(អេ)  ប្រាក់កម្ចីសំរាប់បង់ប្រាក់ខែបុគ្គលិកនិងការចំណាយផ្សេងៗដែលហៅកាត់ថា ភី ភី ភី (PPP) ឬ ប្រាក់កម្ចីសំរាប់ស្រោចស្រង់សេដ្ឋកិច្ចដែលរងផលប៉ះពាល់ពីគ្រោះទុរភិក្សដែលហៅកាត់ថា អ៊ី អាយ ឌី អិល (EIDL) នោះទេ។ ប្រសិនបើមានជនណាម្នាក់ទំនាក់ទំនងមកលោកអ្នក ហើយអះអាងថាជាអ្នកធ្វើការនៅរដ្ឋបាល អេស ប៊ី អេ សូមប្រុងប្រយ័ត្ន ព្រោះវាជាការឆបោក។

- ប្រសិនបើមានជនណាទំនាក់ទំនងមកលោកអ្នក ហើយសន្យាថានឹងជួយអោយលោកអ្នកទទួលបានប្រាក់កម្ចីរបស់រដ្ឋបាល អេស ប៊ី អេ ប៉ុន្តែតម្រូវអោយបង់ប្រាក់ទុកជាមុន ឬ ផ្តល់នូវប្រាក់កម្ចីភ្លាមៗអោយលោកអ្នកខ្ចីជាមុនសិនដោយគិតអត្រាការប្រាក់ខ្ពស់ សូមប្រុងប្រយ័ត្ន ព្រោះវាជាការឆបោក។

- ប្រាក់កម្ចីសំរាប់បង់ប្រាក់ខែបុគ្គលិកនិងការចំណាយផ្សេងៗដែលហៅកាត់ថា ភី ភី ភី (Payroll Protection Program loans) នឹងផ្តល់ជូនតាមរយៈ ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីក្នុងកម្មវិធី ៧(អេ)ដែលមានការទទួលស្គាល់យ៉ាងត្រឹមត្រូវពីរដ្ឋបាល អេស ប៊ី អេ។ រដ្ឋបាល អេស ប៊ី អេ កំពុងពង្រីកចំនួនក្រុមហ៊ុនផ្តល់ប្រាក់កម្ចីដែលអាចផ្តល់ប្រាក់កម្ចី ភី ភី ភី។ ក្នុងករណីដែលលោកអ្នកមិនដឹងច្បាសអំពីក្រុមហ៊ុន

ផ្តល់ប្រាក់កម្ចីណាមួយមានលក្ខខ័ណ្ឌគ្រប់គ្រាន់និងត្រឹមត្រូវនោះ សូមទំនាក់ទំនងទៅកាន់ការិយាល័យរដ្ឋបាល អេស ប៊ី អេ ប្រចាំតំបន់របស់លោកអ្នក។

- ការចុះឈ្មោះ និងការបិទសំណើរខ្ចីប្រាក់របស់កម្មវិធីប្រាក់កម្ចី ភី ភី ភី (PPP) ឬកម្មវិធីប្រាក់កម្ចី អ៊ី អាយ ឌី អិល (EIDL) គឺមិនមានការបង់ប្រាក់ទេ។ រដ្ឋាភិបាលនឹងរ៉ាប់រងរាល់ការបង់ថ្លៃជូនក្រុមហ៊ុនផ្តល់ប្រាក់កម្ចីទាំងអស់។

- ប្រសិនបើលោកអ្នកកំពុងចុះឈ្មោះស្នើរសុំប្រាក់កម្ចី អេស ប៊ី អេ ហើយទទួលបានអ៊ីមែលដែលសួរអំពីពត៌មានផ្ទាល់ខ្លួនរបស់អ្នក ត្រូវពិនិត្យថាតើលេខសំគាល់សំណុំរឿងខ្ចីប្រាក់ដែលមានយោងក្នុងអ៊ីមែល ដូចគ្នានឹងលេខសំគាល់សំណុំរឿងពេលដាក់ពាក្យសុំដែរទេ។

**សម្រាប់ពត៌មានបន្ថែម** សូមចូលទៅកាន់៖ https://www.sba.gov/document/report--sba-programs-scams-fraud-alerts

ប្រសិនបើលោកអ្នកមានរឿងរ៉ាវទាក់ទងនឹងបញ្ហាប្រាក់កម្ចីនេះ សូមអនុញ្ញាត្តិជួយប្រាប់ដល់ អង្គការអ្នកធ្វើអាជីវកម្មខ្នាតតូចភាគច្រើន (Small Business Majority) បានដឹងផង។ សូមចូលទៅកាន់គេហទំព័រនេះ ដើម្បីប្រាប់និងធ្វើការស្ទង់មតិ៖ https://www.surveymonkey.com/r/5F2VKFG (ជាភាសាអង់គ្លេសតែប៉ុណ្ណោះ)

## នៅពេលដែលលោកអ្នកស្វែងរកប្រាក់កម្ចីពីប្រភពផ្សេងៗទៀត

មុនពេលលោកអ្នកដាក់ពាក្យសុំប្រាក់កម្ចី វាជាការចាំបាច់ណាស់ដែលលោកអ្នកត្រូវចេះសួរសំណួរអោយចំគោលដៅចំពោះក្រុមហ៊ុនផ្តល់ប្រាក់កម្ចី ឬឈ្មួញកណ្តាល។ ខាងក្រោមនេះគឺជាបញ្ជីត្រួតពិនិត្យសំរាប់ណែនាំលោកអ្នកក្នុងកំឡុងពេលដំណើរការខ្ចីប្រាក់នេះ។ សម្រាប់ចំនុចគន្លឹះ និងការណែនាំបន្ថែមទៀត សូមចូលទៅកាន់គេហទំព័រ Venturize.org ។

### បញ្ជីត្រួតពិនិត្យ

❒ តើខ្ញុំត្រូវបង់អត្រាការប្រាក់ប្រចាំឆ្នាំប៉ុន្មាន? សូមកត់ត្រាទុកប្រសិនបើលោកអ្នកទទួលបានចម្លើយដែលមិនបានឆ្លើយចំនឹងសំនួររបស់អ្នក។ ការដឹងពីអត្រាការប្រាក់ប្រចាំឆ្នាំ នឹងជួយលោកអ្នកក្នុងការប្រៀបធៀបការប្រាក់របស់ជម្រើសផ្សេងៗទៀត។

❒ តើការបង់ថ្លៃសេវាទាំងអស់មានអ្វីខ្លះ? តើការបង់ថ្លៃនេះគិតរួមបញ្ចូលជាមួយអត្រាការប្រាក់ដែលបានផ្តល់ជូនហើយឬនៅ? តើចំនួនទឹកប្រាក់ត្រូវបង់មានចំនួនប៉ុន្មានដែរ ហើយត្រូវបង់ចំនួនប៉ុន្មានដងដែរ?

❒ តើប្រាក់កម្ចីទាំងមូលតែម្តង (ទាំងការ ទាំងដើម) មានចំនួនប៉ុន្មានដែរ?

❒ ប្រសិនបើខ្ញុំបង់ផ្តាច់អោយអស់មុនការកំណត់ តើខ្ញុំចាំបាច់ត្រូវបង់ប្រាក់អ្វីផ្សេងក្រៅពីប្រាក់ដើមដែរឬទេ? ប្រសិនបើត្រូវបង់ តើតំលៃនៃការបង់ផ្តាច់មានចំនួនប៉ុន្មានដែរ? ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីខ្លះនៅតែគិតការប្រាក់និងថ្លៃសេវាពីអ្នក បើទោះបីជាអ្នកបង់ប្រាក់ផ្តាច់អោយអស់មុនថ្ងៃកំណត់ក៏ដោយ។ ថ្វីត្បិតតែវាត្រូវអស់ថ្លៃសេវាផ្សេងៗ ក្រុមហ៊ុនផ្តល់ប្រាក់កម្ចីអាចពន្យល់ថ្លៃសេវានេះ ថាជាការចុះភាគរយចំពោះការបង់ផ្តាច់ជាមុន។

❒ ប្រសិនបើថ្ងៃមុខ ខ្ញុំខ្ចីប្រាក់ជាលើកទីពីរពីអ្នក តើខ្ញុំនឹងតំរូវអោយបង់ការប្រាក់ដ៏ទៅពីរដងដែរឬទេ? នេះមានន័យថា តើខ្ញុំនឹងត្រូវបង់ការប្រាក់ពីលើប្រាក់កម្ចីដែលខ្ញុំកំពុងតែមានពីការខ្ចីលើកមុនដែរឬទេ?

❒ តើក្រុមហ៊ុននឹងមានដាក់កាលបរិច្ឆេតតំរូវអោយលោកអ្នកយល់ព្រមទទួលយកប្រាក់កម្ចីឆាប់ៗដែរឬទេ? ក្រុមហ៊ុនមិនគួរដាក់សំពាធលើលោកអ្នក អោយលោកអ្នកសំរេចចិត្តឆាប់ៗក្នុងការយល់ព្រមទទួលយកប្រាក់កម្ចី ឆាប់ៗទៅតាមអំពើចិត្តរបស់ពួកគេបាននោះទេ។

❒ តើក្រុមហ៊ុននឹងរាយការណ៍អំពីព័ត៌មានទាក់ទងនឹងការសងប្រាក់កម្ចីរបស់ខ្ញុំទៅអោយការិយាល័យតាមដានពិន្ទុក្រេឌីតធំៗ ដែលអាចអោយខ្ញុំសន្សំពិន្ទុក្រឌីតរបស់ខ្ញុំដែរឬទេ?

❒ តើអ្នកនឹងរាយការណ៍អំពីពត៌មានវិជ្ជមានព្រមទាំងពត៌មានអវិជ្ជមានដែរឬយ៉ាងណា? ប្រសិនបើខ្ញុំគ្មានលទ្ធភាពបង់ តើអ្នកនឹងព្យាយាមទារបំណុលពីខ្ញុំដោយរបៀបណាដែរ?

❒ ប្រសិនបើលោកអ្នកទាក់ទងខ្ចីប្រាក់តាមរយៈឈ្មួញកណ្តាល សូមសាកសួរ៖

  ❒ តើអត្រាការប្រាក់ប្រចាំឆ្នាំសម្រាប់ជម្រើសកម្ចីនីមួយៗ ដែលអ្នករៀបរាប់ប្រាប់ខ្ញុំនោះមានតំលៃប៉ុន្មានដែរ?

  ❒ ក្នុងនាមជាឈ្មួញកណ្តាល តើអ្នកនឹងទទួលបានកម្រៃពីផ្នែកសេវាកម្មសម្រាប់ជម្រើសនីមួយៗ ពីខ្ញុំជាអ្នកខ្ចី ឬពីអ្នកផ្តល់ប្រាក់កម្ចី? តើអ្នកទទួលបានកម្រៃច្រើនដែរឬទេ ប្រសិនបើខ្ញុំខ្ចីលុយក្នុងកម្រិតណាមួយ?

- ❐ តើខ្ញុំអាចសុំមើលព័ត៌មានសង្ខេបអំពីប្រភេទប្រាក់កម្ចីរបស់អ្នកខ្ចីលុយដែលអ្នកជួយបានសំរេចបានដែរឬទេ? តើអត្រាការប្រាក់ជាមធ្យមគឺប៉ុន្មានដែរ? តើមានមនុស្សប៉ុន្មាននាក់ដែលជ្រើសរើសប្រាក់កម្ចីពីធនាគារ ប្រាក់កម្ចីតាមប្រព័ន្ធអនឡាញក្នុងរយៈពេលមធ្យម ប្រាក់កម្ចីដែលអាចបើកជាសាច់ប្រាក់សុទ្ធមុនសំរាប់អាជីវករយកទៅប្រើប្រាស់ ឬប្រាក់កម្ចីក្នុងរយៈពេលខ្លី។

**យើងខ្ញុំសូមលើកទឹកចិត្តលោកអ្នកអោយយល់ដឹងអំពីសិទ្ធិរបស់លោកអ្នកក្នុងនាមជាអ្នកខ្ចីប្រាក់ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលយើងខ្ញុំបានចូលរួមតាក់តែងច្បាប់នេះឡើងក្នុងនាមជាសមាជិកនៃអង្គការសម្ព័ន្ធភាពសំរាប់ការផ្តល់ប្រាក់កម្ចីសម្រាប់ការធ្វើជំនួញប្រកបដោយទំនួលខុសត្រូវខ្ពស់ (Responsible Business Lending Coalition)**។ ខាងក្រោមនេះគឺជាសិទ្ធិមូលដ្ឋានគ្រឹះផ្នែកហិរញ្ញវត្ថុ ដែលយើងខ្ញុំជឿជាក់ថាគ្រប់អាជីវកម្មខ្នាតតូចទាំអស់គួរតែទទួលបាន ប៉ុន្តែផ្ទុយទៅវិញ ក្នុងករណីជាច្រើន ដែលសិទ្ធិទាំងនេះមិនទាន់ត្រូវបានគាំពារដោយច្បាប់នៅឡើយ។ សិទ្ធិទាំងនោះមានដូចជា៖

- សិទ្ធិទទួលបានតម្លាភាពតម្លៃ និងលក្ខខ័ណ្ឌ ដែលមានប្រាប់ច្បាស់លាស់
- សិទ្ធិទទួលបានផលិតផលដោយគ្មានការរំលោភបំពាន
- សិទ្ធិទទួលបានការសរសេរវាយតំលៃពីហានិភ័យសំរាប់ការផ្តល់កម្ចីដែលប្រកបដោយការទទួលខុសត្រូវខ្ពស់
- សិទ្ធិទទួលបានការអោយតំលៃស្មើគ្នាមិនលំអៀងពីសំណាក់ឈ្មួញកណ្តាល
- សិទ្ធិទទួលបានព័ត៌មានពិន្ទុក្រេឌីតដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ
- សិទ្ធិទទួលបានការអនុវត្តន៍ការទារបំណុលរបស់ក្រុមហ៊ុនប្រកបដោយភាពយុត្តិធម៌

ស្វែងយល់បន្ថែមតាមរយៈ៖ http://www.borrowersbillofrights.org/bill-of-rights.html

ឯកសារនេះត្រូវបានបកប្រែដោយមានការចាប់ដៃគូរជាមួយអង្គកាសម្ព័ន្ធភាពរអភិវឌ្ឍសហគមន៍អាស៊ីប៉ាស៊ីហ្វិក (the National Coalition for Asian Pacific Americans Community Development www.nationalcapacd.org) ក្រោមជំនួយពី មូលនិធិ អេវីង ម៉ារុង ខុហ្វមែន (the Ewing Marion Kauffman Foundation)។